# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTRADE BULLETIN

## INSIDE

**Infographic**
"Understanding Rules of Origin for Export via RCEP"

**Local | Global News**

**Opinion Paper**
"Common Ownership and Competition Law's Infringements"

**Research Paper**
"Potential Impact of RCEP and Structural Transformation on Cambodia"

វ៉ុល០១ | លេខ០៤ | ខែមេសា ឆ្នាំ២០២២
VOLUME 01 | ISSUE 04 | APRIL 2022

# UNDERSTANDING RULES OF ORIGIN FOR EXPORT VIA RCEP

## Why Rules of Origin Matters in RCEP Negotiation?



Identifying the genuine beneficiaries




Distinguishing between preferential and non-prefential tariffs

## RCEP Countries' Ratification Status




## What Exporter needs to know to determine Rules of Origin?



- Destination Country
- Product Harmonized System Codes
- Rule of Origin for Specific Products

## How to get Certificate of Origin?



**WHOLLY OBTAINED OR WHOLLY PRODUCED**

OR

**PRODUCED EXCLUSIVELY FROM ORIGINATING MATERIALS**

OR

**PRODUCT-SPECIFIC RULE**

- Regional Value Content ≥ 40% (RVC40)
- Change of Chapter, Tariff Heading, or Tariff Sub-Heading (CC, CTH, CTSH)
- Chemical Reaction Rule (CR)

**RVC40:** Goods with materials no less than 40% originated in RCEP.
**CC:** Goods changed in two-digit HS code.
**CTH:** Goods changed in four-digit HS code.
**CTSH:** Goods changed in six-digit HS code.
**CR:** Goods undergone chemical reaction process.

## Necessary Export Documents

1. Bill of Landing
2. Packing Lists
3. Commercial Invoice
4. Insurance Certificate (if required by buyer)
5. Certificate of Origin (Ministry of Commerce)
6. Sanitary and Phytosanitary Certificate for Agricultural Goods (Ministry of Agriculture, Forestry and Fisheries)
7. Customs Declaration




Please scan the following documents:

RCEP Rule of Origin | MOC CO Automation | iTrade Bulletin Vol 1 Issue 04

Organized by:

# វិធានដើមកំណើតទំនិញ សម្រាប់ការនាំចេញក្រោមកិច្ចព្រមព្រៀងអាស៊ាន

## ហេតុអ្វីបានជាវិធានដើមកំណើតទំនិញចាំបាច់ក្នុងការចរចា?



កំណត់ថានរណាជាអ្នកទទួលបានផលប្រយោជន៍ពិតប្រាកដ




បែងចែករវាងពន្ធអនុគ្រោះ និងពន្ធទូទៅ

## ការផ្តល់សច្ចាប័ន របស់ប្រទេសសមាជិកអាស៊ាន



**ប្រទេសសមាជិកអាស៊ាន ដែលបានផ្តល់សច្ចាប័នរួចរាល់**

- ប្រ៊ុយណេ
- កម្ពុជា
- ឡាវ
- ម៉ាឡេស៊ី
- មីយ៉ាន់ម៉ា
- សិង្ហបុរី
- ថៃ
- វៀតណាម
- អូស្ត្រាលី
- ចិន
- ជប៉ុន
- នូវែលសេឡង់
- កូរ៉េខាងត្បូង

**ប្រទេសសមាជិកអាស៊ាន ដែលមិនទាន់បានផ្តល់សច្ចាប័ន**

- ឥណ្ឌូនេស៊ី
- ហ្វីលីពីន

## អ្វីដែលអ្នកនាំចេញត្រូវដឹង ដើម្បីកំណត់វិធានប្រភពដើមទំនិញ?



- នាំចេញទៅប្រទេសណា
- ទំនិញស្ថិតក្នុងលេខកូដ HS មួយណា
- ពិនិត្យមើលវិធានប្រភពដើមកំណើតទំនិញនៃផលិតផលនីមួយៗ

## តើនីតិវិធីអ្វីខ្លះដើម្បីទទួលបានវិញ្ញាបនបត្រប្រភពដើមទំនិញ?



ទំនិញដែលបានកកើតទាំងស្រុង ឬទទួលបានទាំងស្រុង

ឬ

ទំនិញដែលត្រូវបានផលិតទាំងស្រុង ពីវត្ថុធាតុមានដើមកំណើត ពីសមាជិកណាមួយ ឬច្រើននៃអាស៊ាន

ឬ

វិធានជាក់លាក់សម្រាប់ផលិតផល

- សមាសធាតុតម្លៃតំបន់ ≥ 40% (RVC40)
- ការផ្លាស់ប្តូរចំណាត់ថ្នាក់បន្ទាត់ពន្ធគយ (CC, CTH, CTSH)
- វិធានប្រតិកម្មគីមី (CR)

## ឯកសារចាំបាច់សម្រាប់នាំចេញ

១. អញ្ញត្តិបណ្ណដឹកជញ្ជូន
២. តារាងវេចខ្ចប់
៣. វិក្កយបត្រពាណិជ្ជកម្ម
៤. វិញ្ញាបនបត្រធានារ៉ាប់រង
 (ប្រសិនបើបានទាមទារដោយអ្នកទិញ)
៥. វិញ្ញាបនបត្រប្រភពដើមទំនិញ
 (ក្រសួងពាណិជ្ជកម្ម)
៦. វិញ្ញាបនបត្រ អនាម័យនិងភូតគាមអនាម័យសម្រាប់ទំនិញកសិកម្ម
 (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)
៧. ប្រតិវេទន៍គយ




**RVC40:** ទំនិញដែលមានធាតុផ្សំក្នុងតំបន់អាស៊ានមិនតិចជាង៤០%
**CC:** ទំនិញដែលត្រូវបានផ្លាស់ប្តូរលេខកូដ HS ២ខ្ទង់
**CTH:** ទំនិញដែលត្រូវបានផ្លាស់ប្តូរលេខកូដ HS ៤ខ្ទង់
**CTSH:** ទំនិញដែលត្រូវបានផ្លាស់ប្តូរលេខកូដ HS ៦ខ្ទង់
**CR:** ទំនិញដែលបានឆ្លងកាត់ដំណើរការប្រតិកម្មគីមី

សូមស្កេនទីនេះដើម្បីទាញយកឯកសារ

វិធានប្រភពដើមទំនិញអាស៊ាន | ប្រព័ន្ធស្វ័យប្រវត្តិកម្មផ្តល់វិញ្ញាបនបត្រប្រភពដើមទំនិញ | ព្រឹត្តិបត្រពាណិជ្ជកម្ម លេខរៀងទី៤

រៀបចំដោយ

## ការព្យាករ៖ កំណើនសេដ្ឋកិច្ចរបស់កម្ពុជាពី៥,៣ % ក្នុងឆ្នាំ២០២២ និង ៦,៥% ក្នុងឆ្នាំ២០២៣[1]

ប្រភព៖ Asian Development Bank

សេដ្ឋកិច្ច ត្រូវបានព្យាករថានឹងមានកំណើនពី ៥,៣ % នៅឆ្នាំ២០២២ និង ៦,៥% នៅឆ្នាំ២០២៣។ កំណើនសេដ្ឋកិច្ចនៃដៃគូពាណិជ្ជកម្មសំខាន់ៗ នឹងបន្តគាំទ្រដល់សន្ទុះខ្លាំងនៃការនាំចេញទំនិញរបស់កម្ពុជា និងលំហូរនៃការវិនិយោគផ្ទាល់ពីបរទេស។ ទិន្នផលឧស្សាហកម្មត្រូវបានគេរំពឹងថានឹងកើនឡើងពី ៨,១% ក្នុងឆ្នាំ២០២២ និង ៩,១% ក្នុងឆ្នាំ២០២៣។ កំណើននៃផ្នែកសម្លៀកបំពាក់ ទំនិញធ្វើដំណើរ និងស្បែកជើងនឹងត្រូវបានជំរុញដោយតម្រូវការខាងក្រៅដ៏រឹងមាំ ដែលគាំទ្រដោយការផ្លាស់ប្តូរទីតាំងនៃការបញ្ជាទិញពីប្រទេសចិន និងប្រទេសជិតខាង។ កំណើននេះក៏នឹងត្រូវបានជំរុញដោយការអនុវត្តនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ ដើម្បីបង្កើនការប្រកួតប្រជែងនៅក្នុងផ្នែកនេះ។ កំណើននៃផលិតកម្មមិនមែនកាត់ដេរគួរតែឆ្លុះបញ្ចាំងពីតម្រូវការខាងក្រៅដ៏រឹងមាំ ដែលត្រូវបានគាំទ្រដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយប្រទេសចិននិងកូរ៉េខាងត្បូង និងច្បាប់វិនិយោគថ្មី។ ទិន្នផលកសិកម្មត្រូវបានគេរំពឹងថានឹងកើនឡើងក្នុងអត្រា ១,២% លើសពីការព្យាករ។ ចុចទីនេះដើម្បីអានបន្ថែម

## ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិក ជាគន្លឹះសំខាន់សម្រាប់កំណើនសេដ្ឋកិច្ចកម្ពុជា[2]

ប្រភព៖ Khmer Times

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបើកកិច្ចប្រជុំមួយ ដើម្បីពិភាក្សាអំពីផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍវិស័យយានយន្ត និងអេឡិចត្រូនិករបស់កម្ពុជា។ បន្ទាប់ពីកិច្ចប្រជុំនេះ ឯកសារចំនួនពីរត្រូវបានរៀបចំឡើង។ ឯកសារទីមួយគឺ "ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍ និងការទាក់ទាញការវិនិយោគក្នុងវិស័យយានយន្ត" ដែលកំណត់គោលដៅអភិវឌ្ឍន៍វិស័យយានយន្តរបស់កម្ពុជា ហើយភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃក្នុងតំបន់ និងពិភពលោក និងមានបំណងលើកកម្ពស់ការផលិតគ្រឿងបង្គុំរថយន្តដែលស្មុគស្មាញជាងមុន និងមានតម្លៃបន្ថែមកាន់តែខ្ពស់។ ឯកសារទីពីរគឺ "ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍ និងការទាក់ទាញការវិនិយោគក្នុងវិស័យអេឡិចត្រូនិក" ដែលមានគោលបំណងផលិតគ្រឿងបន្លាស់អេឡិចត្រូនិកយ៉ាងទូលំទូលាយ សមាសធាតុពាក់កណ្តាលសម្រេច ផលិតផលដំឡើងបន្ទាប់ និងផលិតផលដែលបានដំឡើងយ៉ាងពេញលេញ ដើម្បីបម្រើទីផ្សារនាំចេញក្នុងតំបន់ និងពិភពលោក។ ចុចទីនេះដើម្បីអានបន្ថែម

[1] បកប្រែក្រៅផ្លូវការ

[2] បកប្រែក្រៅផ្លូវការ

## ពាណិជ្ជកម្មត្រីមាសទី១របស់កម្ពុជា ស្ទុះឡើងវិញដោយសារតែ ការដោះស្រាយវិបត្តិកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាព និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី[3]

ប្រភព៖ Khmer Times

ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋាភិបាលចំពោះវិបត្តិកូវីដ-១៩ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗ បានជួយជំរុញពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជានៅក្នុងត្រីមាសទី១នៃឆ្នាំនេះ។ តាមរបាយការណ៍ចុងក្រោយរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករបានឱ្យដឹងថា ពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជាកើនដល់ ១៣,១ ប៊ីលានដុល្លារអាម៉េរិក ក្នុងអំឡុងខែមករាដល់ខែមីនា ឆ្នាំ២០២២ កើនឡើង ៩,១% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ របាយការណ៍បានបង្ហាញថា ទំហំនាំចេញកើនដល់ ៥,៧ ប៊ីលានដុល្លារអាម៉េរិក គឺកើនឡើង ២៥,៧% ហើយទំហំនាំចូលមានតម្លៃ ៧,៤ ប៊ីលានដុល្លារអាម៉េរិក គឺធ្លាក់ចុះ ០,៩%។ ចុចទីនេះដើម្បីអានបន្ថែម

## គល់ស្លឹកគ្រៃពូជត្លុកដំរីត្រៀមនាំចេញទៅកាន់ការណាដាឆាប់ៗនេះ

ប្រភព៖ Cambonomist

ស្លឹកគ្រៃប្រភេទ «ត្លុកដំរី» កំពុងមានតម្រូវការទីផ្សារខ្លាំងទាំងទីផ្សារក្នុងស្រុក និងការនាំចេញពិសេសទីផ្សារនៅប្រទេសថៃ ដែលកន្លងមក ថៃមានតម្រូវការស្លឹកគ្រៃប្រភេទត្លុកដំរីនេះពីកម្ពុជា រហូតដល់ ១០០តោន ក្នុងមួយសប្តាហ៍។ បច្ចុប្បន្ននេះ សហគមន៍ដាំស្លឹកគ្រៃនេះ ក៏កំពុងត្រៀមនាំចេញទៅប្រទេសកាណាដាផងដែរ ដោយសារដំណើរការនៃការនាំចេញស្លឹកគ្រៃប្រភេទនេះទៅទីផ្សារថៃត្រូវបានរំខានដោយសារតែការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ប្រភេទអូមីក្រុង។ លោក នាក់ ភា ប្រធានសហគមន៍ស្ទួលទ្រេតបានលើកឡើងថា គល់ស្លឹកគ្រៃត្លុកដំរីសម្រាប់នាំចេញទៅទីផ្សារកាណាដា មានតម្លៃ ១,៨០០រៀល ក្នុងមួយគីឡូក្រាម ដែលតម្លៃសហគមន៍ទិញពីកសិករគឺ ១,២០០រៀល ក្នុងមួយគីឡូក្រាម។ តម្លៃនេះហាក់មិនទាន់ផ្តល់ផលចំណេញដល់អ្នកនាំចេញនៅឡើយ ដោយសារតែចំណាយលើថ្លៃដើមនៅមានអាត្រាខ្ពស់នៅឡើយ។ ចុចទីនេះដើម្បីអានបន្ថែម

---

[3] បកប្រែក្រៅផ្លូវការ

## Cambodia Growth Projection At 5.3% in 2022 And 6.5% in 2023

Source: Asian Development Bank

The economy is forecast to grow by 5.3% in 2022 and 6.5% in 2023. Growth in the economies of major trading partners will continue to support the strong momentum of Cambodia's merchandise exports and inflows of foreign direct investment. Industry output is expected to grow by 8.1% in 2022 and 9.1% in 2023. Growth in the garments, travel goods, and footwear segment will be driven by strong external demand supported by a relocation of orders from the People's Republic of China and neighboring countries. This growth will also be buoyed by the implementation of the Garments, Footwear and Travel Goods Development Strategy to raise competitiveness in this segment. Growth of non-garment manufacturing should reflect expected strong external demand supported by recent free trade agreements with the People's Republic of China and the Republic of Korea and a new investment law. Agriculture output is expected to grow at 1.2% over the forecast horizon. Click here to read more

## Auto, Electronics Development Key for Cambodia's Growth

Source: Khmer Times

The Ministry of Economy and Finance held a meeting to discuss a roadmap for developing Cambodia's automotive and electronics sectors. Following the meeting, two documents were prepared. First, the 'Roadmap for the Development and Attraction of Investment in the Automotive Sector' targets the development of Cambodia's automotive sector and links it to the regional and global value chain. It intends to promote the production of more complex vehicle components and higher value-added. Second, the 'Roadmap for the Development and Attraction of Investment in the Electronics Sector' which aims to produce a wide range of electronic components, semi-finished components, sub-assembled products and fully assembled products to serve the regional and global export markets. Click here to read more.

## Cambodia's Q1 Trade Jumps on Covid-19 Handling, FTAs

Source: Khmer Times

The government's effective handling of the Covid-19 crisis and various Free Trade Agreements (FTAs) helped boost Cambodia's international volume in the first quarter of this year. The Kingdom's international trade reached $13.1 billion during the January-March period in 2022, up 9.1 percent compared to the same period last year, according to the General Department of Customs and Excise (GDCE)'s latest report. The export volume reached $5.7 billion, up 25.7 percent, and the import volume was valued at $7.4 billion, a slight drop of 0.9 percent, the report said. Click here to read more

## Ivory Lemongrass Ready to Reach Canada's Market Soon[4]

Source: Cambonomist

Cambodia's "Ivory" lemongrass is in great demand in both domestic and foreign markets, especially in Thailand into which up to 100 tons per week from Cambodia were exported in the past. Presently, the lemongrass growing community is getting prepared for export to Canada as the demand in Thailand is facing turbulence due to the Omicron rise. According to Neak Phea, head of the Snuol Tret community, the price of lemongrass for export to Canada is 1,800 riel/kg, only 600 riel/kg over the 1,200 riel/kg the community buys from farmers. As such, the profit margin for traders from this lemongrass product is not remarkable yet as the production cost is still relatively high. Click here to read more

[4] Unofficial translation

## សង្គ្រាមអ៊ុយក្រែននាំឱ្យ អង្គការពាណិជ្ជកម្មពិភពលោក កាត់បន្ថយការព្យាករកំណើន នៃពាណិជ្ជកម្មសកលសម្រាប់ឆ្នាំនេះ

ប្រភព៖ BBC

លោកជំទាវ អ្ងូកូនចូ អ៊ីវ៉ាឡា អគ្គនាយិកានៃអង្គការ WTO បានមានប្រសាសន៍ថា ការព្យាករកំណើន ៤,៧% កន្លងទៅត្រូវបានកាត់បន្ថយមកនៅត្រឹមតែ ២,៥% ដោយសារតែ "ផល ប៉ះពាល់នៃសង្គ្រាម និងគោលនយោបាយពាក់ព័ន្ធនានា" ការកាត់បន្ថយនេះ ក៏ត្រូវបានភ្ជាប់ទៅនឹងបញ្ហាដែលកំពុងបន្តកើតមាន នៃខ្សែច្រវាក់តម្លៃសកល ដែលជាលទ្ធផលនៃជំងឺរាតត្បាត។ លោកជំទាវបន្តថា ការរំខាននេះអាចបង្កឱ្យម្ហូបអាហារមានតម្លៃថ្លៃ "ការព្រួយបារម្ភរបស់ខ្ញុំ គឺយើងមានវិបត្តិម្ហូបអាហារដែលកំពុងកើតមាន"។ លោកជំទាវ បានព្រមានថា "ខ្ញុំពិតជាព្រួយបារម្ភអំពីភាពអត់ឃ្លាន ជាពិសេសនៅក្នុងប្រទេសក្រីក្រ ដែលយ៉ាងហោចណាស់អាចមានលទ្ធភាពទិញវាបាន"។ វិស័យពាណិជ្ជកម្មបានក្លាយជាឧបករណ៍សំខាន់ ដែលប្រទេសជាច្រើនបានប្រើប្រាស់ ដើម្បីដាក់សម្ពាធលើ លោកប្រធានាធិបតី វ្ល៉ាឌីមៀ ពូទីន លើការឈ្លានពានប្រទេសអ៊ុយក្រែន។ ប្រទេសអ៊ុយក្រែន បានកាត់ផ្តាច់ចំណងសេដ្ឋកិច្ចជាមួយ ប្រទេសរុស្ស៊ី និងនាំឱ្យមានការអំពាវនាវឱ្យព្យួរប្រទេសរុស្ស៊ី ពីសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ព្រោះសង្គ្រាម។ ទោះបីជាយ៉ាងណា ពុំមានប្រទេសណាមួយ ត្រូវបានបណ្តេញចេញពី WTO នោះទេ នេះជាអ្វីមួយដែលអគ្គនាយិកាបាន លើកឡើង "មិនមែនជារឿងងាយស្រួលធ្វើទេ" លោកជំទាវបានមានប្រសាសន៍ថា ពុំមានយន្តការណាមួយ ដើម្បីបណ្តេញប្រទេសរុស្ស៊ីចេញនោះទេ ទោះជា មេធាវីពាណិជ្ជកម្មអន្តរជាតិល្បីៗមួយចំនួនមិនយល់ស្របក៏ដោយ។ ចុចទីនេះដើម្បីអានបន្ថែម

## សកលភាវូបនីយកម្ម មិនដំណើរការក្នុងយុគសម័យនៃអសន្តិសុខ យើងត្រូវការដំណោះស្រាយក្នុងស្រុកបន្ថែមទៀត

ប្រភព៖ The Guardian

ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិក្នុងសប្តាហ៍នេះ បានចេញការព្រមានពីហានិភ័យនៃសង្គ្រាមដែលបង្កើនល្បឿន ឱ្យមានការបែងចែកពិភពលោកទៅជាប្លុកសេដ្ឋកិច្ចគូប្រជែង។ ស្ថាប័ននេះមានការព្រួយបារម្ភពីហានិភ័យ នៃការវិលត្រលប់ទៅកាន់ទស្សវត្សរ៍ឆ្នាំ១៩៣០ ដោយបារម្ភពីនិន្នាការពេលបច្ចុប្បន្ន ឆ្ពោះទៅរកការដកសកលភាវូបនីយកម្មដែលជាលទ្ធផល នាំឱ្យរបាំងពាណិជ្ជកម្មមានការកើនឡើង ប្រទេសជាច្រើនអនុវត្តស្តង់ដាបច្ចេកវិទ្យារៀងៗខ្លួន ហើយនិងការលេចឡើងនូវរូបិយបណ្ណបម្រុងជាគូប្រជែង នឹងរូបិយបណ្ណដុល្លារអាមេរិក។ ភាពខុសឆ្គង គឺត្រង់ថាការមើលឃើញសកលភាវូបនីយកម្ម ដូចទៅនឹងពហុភាគីនិយមជាជាងកត្តាជាក់លាក់ណាមួយ នៃមូលធននិយមអន្តជាតិដែលបានកកើតបីទស្សវត្សរ៍ តាំងពីការដួលរលំនៃលទ្ធិកុម្មុយនិស្ត។ ប៉ុន្តែដោយហេតុផលមួយចម្បង សម្រាប់ពិចារណាឡើងវិញ នៃសកលភាវូបនីយកម្ម

[5] បកប្រែក្រៅផ្លូវការ

គឺនយោបាយ ក្នុងយុគសម័យនៃអសន្តិសុខ បានឈានមកដល់ ហើយវាបានជំរុញឱ្យមានប្រតិកម្ម ដែលអាចព្យាករបាន ពីអ្នកបោះឆ្នោតដែលមិនសប្បាយចិត្តអំពីការកើនឡើងថ្លៃរស់នៅ ការធ្លាក់ចុះកម្រិតជីវភាព និងការកើនឡើងវិសមភាព។ ចុចទីនេះដើម្បីអានបន្ថែម

## ការធ្វើពាណិជ្ជកម្ម រវាងប្រទេសចិនជាមួយសមាជិកអាសិប រក្សាបាននូវកំណើនល្អ

ប្រភព៖ Xinhua

ចាប់តាំងពី កិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(អាសិប) ចូលជាធរមាននៅដើមឆ្នាំនេះ យោងតាមទិន្នន័យផ្លូវការចុងក្រោយរបស់អគ្គរដ្ឋបាលគយ បានបង្ហាញថាការធ្វើពាណិជ្ជកម្ម រវាងប្រទេសចិន និងសមាជិក១៤ទៀតនៃអាសិប មានការកើនឡើង ៦,៩% ធៀបនឹងឆ្នាំមុន ឬប្រមាណ ៩៤៨,៦ ប៊ីលានដុល្លារអាម៉េរិក ក្នុង ត្រីមាសទី១ ឆ្នាំ២០២២ ស្មើនឹង ៣០,៤% នៃតម្លៃពាណិជ្ជកម្មអន្តរជាតិសរុបរបស់ប្រទេសចិន។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដ៏ធំនេះ នឹងបង្កើតបរិយាកាសពាណិជ្ជកម្ម ដ៏អនុគ្រោះបំផុតមួយសម្រាប់តំបន់ ដែលកិច្ចព្រមព្រៀងនេះបានចូលជាធរមានចំនួន ១២ប្រទេស ក្នុងចំណោម ១៥ប្រទេស នៃសមាជិកហត្ថលេខី ក្នុងនោះ ១០ប្រទេស បានចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០២២ និងចំនួន ២ប្រទេសទៀត គឺកូរ៉េខាងត្បូង និងម៉ាឡេស៊ី បានចូលជាធរមាននៅថ្ងៃទី០២ ខែកុម្ភៈ និងទី១៨ ខែមីនា ជាបន្តបន្ទាប់។ ចុចទីនេះដើម្បីអានបន្ថែម

## គ្រប់ខណ្ឌសម្រាប់ការប្តេជ្ញាចិត្តបន្តឆ្ពោះទៅកាន់ភាពជោគជ័យនៃអាសិប

ប្រភព៖ East Asia Forum

ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន និងការចូលជាធរមាន នៃកិច្ចព្រមព្រៀងដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់(អាសិប) មិនមែនជាគោលដៅចុងក្រោយរបស់សមាជិកនោះទេ។ កិច្ចព្រមព្រៀងនេះ បង្កើតឡើងតាមវិធីអាស៊ាន ដែលមានន័យថាប្រទេសជាសមាជិកទាំងអស់ ជាពិសេសសមាជិកដែលមិនមែននៅក្នុងតំបន់អាស៊ាន ចាំបាច់ត្រូវធ្វើឱ្យកិច្ចព្រមព្រៀងនេះមានការវិវត្តប្រកបដោយភាពរស់រវើក ដើម្បីធានាការពារផលប្រយោជន៍ នៃរបបពាណិជ្ជកម្ម អាស្រ័យលើវិធានជាមូលដ្ឋាន។ ភូមិសាស្រ្តនយោបាយ គឺជាប្រធានបទដែលកំពុងតែគ្របដណ្តប់ក្នុងការជជែកវែកញែក ពាក់ព័ន្ធនឹងគោលនយោបាយ តាមបណ្តាប្រទេសមួយចំនួន រួមមានប្រទេសជប៉ុនផងដែរ។ មតិជាច្រើនបានអះអាងពីការបញ្ចប់នៃសម័យសកលភាវូបនីយកម្ម ដែលធ្វើឱ្យការពិភាក្សាអំពីកិច្ចការសេដ្ឋកិច្ចរដ្ឋ និងសន្តិសុខសេដ្ឋកិច្ច បានក្លាយជាចំណុចស្នូល។ ចុចទីនេះដើម្បីអានបន្ថែម

## ការជួញដូរប្រេងឆៅកើនឡើងបន្ទាប់ពីមានការបញ្ចេញប្រេងឆៅអាម៉េរិកដែលបានស្តុកទុក

ប្រភព៖ S&P Global Commodity Insights

ការជួញដូរប្រេងឆៅបានកើនឡើងខ្ពស់ នៅតំបន់អាស៊ីនៅព្រឹកថ្ងៃទី២១ ខែមេសា នៅក្នុងចំណោមមូលដ្ឋានផ្គត់ផ្គង់ដែលមានតិចតួច ដោយមានសន្ទុះកើនឡើងពីការបញ្ចេញប្រេងឆៅ និងសន្និធិប្រេងអាម៉េរិក កាលពីសប្តាហ៍មុន។ យោងតាមទិន្នន័យរបស់រដ្ឋបាលព័ត៌មានថាមពលអាម៉េរិក កាលពីថ្ងៃទី២០ ខែមេសា បានបង្ហាញថាសន្និធិប្រេងឆៅពាណិជ្ជកម្ម របស់អាម៉េរិកសរុប បានធ្លាក់ចុះចំនួន៨,០២ លានបារ៉ែល មកនៅត្រឹមតែ ៤១៣,៧៣លានបារ៉ែល ក្នុងសប្តាហ៍ថ្ងៃទី១៥ ខែមេសា ដែលមានការធ្លាក់ចុះជិត១៥% ពីកម្រិតមធ្យមប្រាំឆ្នាំក្នុងអំឡុងពេលដូចគ្នានេះ។ ការធ្លាក់ចុះនេះកើតឡើងស្របពេលដែលការនាំចេញប្រេងឆៅរបស់អាម៉េរិក កើនឡើងចំនួន ២,០៩លានបារ៉ែលក្នុង១ថ្ងៃ ដែលកើនឡើងរហូតដល់៤,២៧ លានបារ៉ែលក្នុង១ថ្ងៃ ដែលជាចំនួនខ្ពស់បំផុតតាំងខែមីនា ឆ្នាំ២០២០។ ជារួម សន្និធិប្រេងទូទាំងប្រទេស បានធ្លាក់ចុះចំនួន ២,៦៦ លានបារ៉ែល មកនៅត្រឹមតែ ១០៨,៧៤លានបារ៉ែល។ ចុចទីនេះដើម្បីអានបន្ថែម

## ជប៉ុនសម្រេចដកឋានៈ "ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត" ពីរុស្ស៊ីជាផ្លូវការ

ប្រភព៖ Asia News Network

កាលពីថ្ងៃពុធ ទី២០ ខែមេសា ឆ្នាំ២០២២ រាជរដ្ឋាភិបាលជប៉ុន បានដកឋានៈពាណិជ្ជកម្ម "ប្រជាជាតិដែលទទួលបានការអនុគ្រោះបំផុត" ពីរុស្ស៊ី ចំពោះការឈ្លានពានរបស់រុស្ស៊ីលើអ៊ុយក្រែន។ ការដកឋានៈពាណិជ្ជកម្មនេះ អនុវត្តចំពោះតែលើពន្ធគយនៃគ្រប់ការនាំចូលរបស់រុស្ស៊ី ដែលអនុញ្ញាតឱ្យទីក្រុងតូក្យូ ដំឡើងពន្ធកាន់តែខ្ពស់លើគ្រប់ទំនិញទាំងអស់របស់រុស្ស៊ី។ សេចក្តីសម្រេចរបស់ជប៉ុននេះ ធ្វើឡើងស្របពេលជាមួយអាម៉េរិក និងប្រទេសសមាជិក G7 ។ ក្នុងខែមីនា ការអនុវត្តទណ្ឌកម្មលើរុស្ស៊ី បានធ្វើឱ្យការនាំចេញរបស់ជប៉ុនទៅកាន់រុស្ស៊ីធ្លាក់ចុះប្រមាណ ៣២% ខណៈការនាំចូលកើនឡើងប្រមាណ៩០%។ ប្រមាណ២ភាគ៣ទាក់ទងនឹងការនាំចូលថាមពល ជាមួយនឹងការកើនឡើងយ៉ាងខ្លាំង ក្នុងការនាំចូលឧស្ម័នធម្មជាតិ ប្រេង និងធ្យូងថ្ម។ គួរឱ្យកត់សម្គាល់ផងដែរ ជប៉ុនកំពុងដើរតួនាទីយ៉ាងសំខាន់ ក្នុងកិច្ចខិតខំប្រឹងប្រែងអន្តរជាតិប្រឆាំងនឹងរុស្ស៊ី ដោយសារការព្រួយបារម្ភពីផលប៉ះពាល់ នៃការឈ្លានក្នុងតំបន់អាស៊ីប៉ូស៊ីហ្វិក ដែលយោធាចិនមានការកើនឡើង ដែលមិនអាចបដិសេធបាន។ ចុចទីនេះដើម្បីអានបន្ថែម

## The Ukraine War Has Led WTO to Cut Its Global Trade Growth Forecast for This Year

Source: BBC

The previous 4.7% growth forecast has been cut to 2.5% due to "the impact of the war and related policies", said WTO boss Dr Ngozi Okonjo-Iweala. The cut is also linked to continuing global supply chain problems that started as a result of the pandemic."I'm truly worried about looming hunger, particularly in poor countries that can least afford it," Dr Okonjo-Iweala warned. Trade has become a key tool many countries have used to pressure President Vladimir Putin over his decision to invade Ukraine. Ukraine has cut economic ties with Russia and led calls for it to be suspended from the WTO because of the war. However, no country has ever been expelled from the WTO, something the Director-General said is "not an easy thing to do". She says there is no mechanism to kick Russia out despite some leading international trade lawyers disagreeing. Click here to read more

## Globalization Not Working – In an Age of Insecurity, We Need More Local Solutions

Source: The Guardian

The International Monetary Fund issued a warning about the risk of the war accelerating the fragmentation of the world into rival economic blocs. The IMF is worried about the risk of a return to the 1930s. It fears the current trend towards deglobalization will result in trade barriers going up, countries adopting their own technological standards – and rival reserve currencies emerging to challenge the supremacy of the US dollar. The mistake is to see globalisation as synonymous with multilateralism rather than the particular variant of international capitalism that has emerged in the three decades since the collapse of communism. But the prime reason for the rethink of globalisation is political. The age of insecurity has arrived and it has prompted a predictable backlash from voters unhappy about the rising cost of living, falling living standards and rising inequality.

## China's Trade with RCEP Members Sustains Steady Growth

Source: Xinhua

Trade between China and members of the Regional Comprehensive Economic Partnership (RCEP) has seen steady growth since the trade agreement took effect at the beginning of this year, the latest official data showed. According to the General Administration of Customs (GAC), China's trade with the other 14 member states expanded 6.9 percent year on year to 2.86 trillion yuan (about 448.6 billion U.S. dollars) in the first quarter of 2022, accounting for 30.4 percent of China's total foreign trade value. The world's largest free trade pact is believed to create a more favorable trade environment in the region. The free trade pact initially entered into force for 10 members on January 01, 2022, followed by South Korea and Malaysia on February 02 and March 18. Up to now, the agreement is effective for 12 of its 15 signing members.

## A Framework for Ongoing Commitments to RCEP Success

Source: East Asia Forum

For member states of the Regional Comprehensive Economic Partnership (RCEP) its signing, ratification and being in effect are by no means the final goal. RCEP is designed in the 'ASEAN Way', meaning members must make it a living and evolving agreement if it is going to help successfully defend the rules-based trading regime. In particular, continuous commitment to RCEP by non-ASEAN member states will be key. Recent policy debates in countries including Japan have been dominated by geopolitics. Discussions of economic statecraft and economic security have taken centre stage and many proclaim the end of the era of globalisation. Click here to read more

## Crude Oil Futures Climb after Draws in US Crude, Product Stocks

Source: S&P Global Commodity Insights

Crude oil futures were higher in mid-morning Asian trade April 21 amid still tight supply fundamentals, with sentiment receiving an extra boost from draws in US crude and product stocks last week. Total US commercial crude stocks fell 8.02 million barrels to 413.73 million barrels in the week ended April 15, US Energy Information Administration data showed April 20, leaving inventories nearly 15% behind the five-year average for this time of the year. The draws come as US crude exports surged 2.09 million b/d to 4.27 million b/d, the highest since March 2020 Further, nationwide distillate stocks fell 2.66 million barrels to 108.74 million barrels. Click here to read more

## Japan Formally Revokes Russia's 'Most Favored Nation' Status

Source: Asia News Network

Japan formally revoked Russia's "most favored nation" trade status Wednesday over its invasion of Ukraine. The revocation of the trade status applies to tariffs on all Russian imports, allowing Tokyo to impose higher duties on such products. It followed a decision along with the U.S. and other Group of Seven member nations. In March, as sanctions took hold, Japan's exports to Russia fell nearly 32% but imports surged nearly 90%. Nearly two-thirds of that was energy related, with sharp increases in imports of natural gas, oil and coal. Japan is taking a greater role in the international effort against Russia because of concerns about the impact of the invasion in East Asia, where China's military has grown increasingly assertive. Click here to read more

# កម្មសិទ្ធិរួម និងការបំពានច្បាប់ស្តីពីការប្រកួតប្រជែង

ដោយលោក កែវ ប៊ុនថេង
ប្រធានការិយាល័យច្បាប់ពាណិជ្ជកម្ម
នាយកដ្ឋាននីតិកម្ម

កម្មសិទ្ធិរួម កើតឡើងនៅពេលវិនិយោគិនកាន់កាប់ភាគហ៊ុនភាគច្រើន ទន្ទឹមនឹងនោះ បាននឹងកំពុងកាន់កាប់មូលបត្រភាគហ៊ុនភាគតិច ឬផលប្រយោជន៍នានានៃកម្មសិទ្ធិ នៅក្នុងក្រុមហ៊ុនដែលកំពុងប្រកួតប្រជែងគ្នា។ កម្មសិទ្ធិរួម ឬអាចហៅថា ការកាន់កាប់ភាគហ៊ុនខ្សែដេក គឺជាវាក្យសព្ទមួយ ដែលឆ្លុះបញ្ចាំងពីការអនុវត្តរបស់វិនិយោគិនជាច្រើន ដែលកាន់កាប់តួនាទីវិនិយោគនៅក្នុងក្រុមហ៊ុនជាច្រើន ដែលមានការប្រកួតប្រជែងគ្នាក្នុងវិស័យតែមួយ។

ដោយសារភាពស្មុគស្មាញជាសារវន្ត មកទល់ពេលនេះ មានការពិភាក្សាដេញដោលជាច្រើន ក្នុងចំណោមអាជ្ញាធរពាក់ព័ន្ធនឹងកិច្ចការប្រកួតប្រជែង។ ជាក់ស្តែង គណៈកម្មការអឺរ៉ុបបានយកចិត្តទុកដាក់យ៉ាងខ្លាំង លើបញ្ហាកម្មសិទ្ធិរួមនេះ នៅក្នុងករណីចំនួនពីរពាក់ព័ន្ធនឹងក្រុមហ៊ុនរួមទុនល្បីៗ រួមមានករណី Dow/Dupont (២០១៧) និងករណី Bayer/Monsanto (២០១៨)។ គណៈកម្មការពាណិជ្ជកម្មសហព័ន្ធរបស់សហរដ្ឋអាមេរិក ក៏បានបើកសវនាការលើករណីកម្មសិទ្ធិរួមកន្លងមក ដែលបង្កឱ្យមានប្រតិកម្មជាច្រើនពីវិនិយោគិន និងក្រុមហ៊ុនផ្តល់សេវាកម្មសន្ទស្សន៍នានា ហើយបញ្ហាកម្មសិទ្ធិរួម និងផលប៉ះពាល់របស់វា ក៏បានក្លាយជាប្រធានបទក្តៅ នៅក្នុងកិច្ចពិភាក្សាតុមូលរបស់អង្គការ OECD កាលពីចុងឆ្នាំ២០១៧ កន្លងទៅ។ បច្ចុប្បន្ននេះ បញ្ហាកម្មសិទ្ធិរួមបានក្លាយជាប្រធានបទដ៏សំខាន់ នៅក្នុងបណ្តាប្រទេសជាច្រើន ដែលបានដាក់ឱ្យអនុវត្តច្បាប់ស្តីពី កិច្ចការប្រកួតប្រជែងរួចហើយ ស្របពេលដែលបញ្ញវន្ត និងអ្នកអនុវត្តច្បាប់ បង្ហាញក្តីបារម្ភកាន់តែច្រើនអំពីផលប៉ះពាល់នៃកម្មសិទ្ធិរួម នៅក្នុងកិច្ចការប្រកួតប្រជែង។ ជាមួយគ្នានេះដែរ ទស្សីករណ៍មួយចំនួនបង្ហាញថា កម្មសិទ្ធិរួម តែងតែបង្កជាការរំលោភបំពានលើច្បាប់ស្តីពីការប្រកួតប្រជែង។

ផ្អែកលើទ្រឹស្តីនៃឥទ្ធិពលសម្របសម្រួល កម្មសិទ្ធិរួមអាចបង្កើតសក្តានុពលខ្ពស់ដល់ការឃុបឃិតគ្នារវាងកម្មសិទ្ធិកររួម ឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដែលមានកម្មសិទ្ធិរួម ឬទាំងពីរ។ ទ្រឹស្តីនេះបកស្រាយថា កម្មសិទ្ធិរួមអាចលើកទឹកចិត្តដល់កម្មសិទ្ធិកររួម ឱ្យជំរុញកិច្ចសម្របសម្រួល នៃផលបត្ររបស់ក្រុមហ៊ុននានា ក្រោមការគ្រប់គ្រងរបស់កម្មសិទ្ធិកររួមនោះ។ ជាគោលការណ៍ ក្នុងលក្ខខណ្ឌទីផ្សារមួយចំនួន (រួមមានតម្លាភាពនៃ ទីផ្សារ និងសភាគនៃផលិតផល) ឥទ្ធិពលសម្របសម្រួលកើតឡើងនៅពេលក្រុមហ៊ុនដែលមាន កម្មសិទ្ធិរួម ឬការទទួលបាន/ការទិញនៃកម្មសិទ្ធិ អាចបង្កើនលទ្ធភាពដល់ភាគីដែលចូលរួមទុន និងដៃគូប្រកួតប្រជែងរបស់ពួកគេ ក្នុងការសម្របសម្រួលការធ្វើពាណិជ្ជកម្ម ឬវិនិយោគក្នុងរូបភាពដែលមិនមានការប្រជែងគ្នា តួយ៉ាងដូចជាការដំឡើងថ្លៃរួមគ្នា ជាដើម។

ស្រដៀងគ្នានេះដែរ ទ្រឹស្តីនៃឥទ្ធិពលឯកតោភាគី បង្ហាញថា ការកាន់កាប់ភាគហ៊ុនរួម អាចបង្កឱ្យមានការកើនឡើងនៃថ្លៃផលិតផល ឬសេវាកម្មក្នុងរយៈពេលខ្លី ព្រមទាំងការធ្លាក់ចុះនៃគុណភាព

ភាពចម្រុះ ឬនវានុវត្តន៍នៃផលិតកម្ម ដោយសារតែក្រុមហ៊ុនទាំងនោះ មិនទទួលបានការលើកទឹកចិត្តក្នុងការធ្វើនវានុវត្តន៍ ដើម្បីប្រជែងក្នុងទីផ្សារឡើយ។ ក្នុងស្ថានភាពនេះ ផលប៉ះពាល់ដែលកើតចេញពីការប្រឆាំងការប្រកួតប្រជែងនេះ នឹងបង្កើតជាទម្រង់នៃឥទ្ធិពលឯកតោភាគី (ឧ. កើតចេញពីការប្រតិបត្តិនៃក្រុមហ៊ុននីមួយៗ ដែលមានកម្មសិទ្ធិរួម)។ ក្នុងទ្រឹស្តីនេះ ក្នុងបរិបទដែលម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនមួយ បាននឹងកំពុងកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនប្រកួតប្រជែងផ្សេងទៀត ម្ចាស់ភាគហ៊ុនដែលមានកម្មសិទ្ធិរួមនេះ តែងរំពឹងទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនប្រកួតប្រជែងផ្សេងទៀតនោះ។ ក្នុងទិដ្ឋភាពនៃផលបត្រ សេណារីយ៉ូនេះ នឹងលើកទឹកចិត្តអ្នកគ្រប់គ្រងក្រុមហ៊ុនផ្សេងៗដែលប្រជែងគ្នា ជាមួយក្រុមហ៊ុនរៀបរាប់ខាងលើ កាត់បន្ថយការប្រកួតប្រជែងគ្នានៅក្នុងទីផ្សារ។ អ្នកដែលគាំទ្រទ្រឹស្តីឥទ្ធិពលឯកតោភាគីនេះ បានលើកឡើងផងដែរថា ផ្អែកលើរចនាសម្ព័ន្ធនៃការកាន់កាប់ភាគហ៊ុនរួម កម្មសិទ្ធិកររួមទាំងនេះនឹងមានលទ្ធភាពក្នុងការបង្កើតឥទ្ធិពល លើការគ្រប់គ្រងក្នុងក្រុមហ៊ុនដែលមានកម្មសិទ្ធិរួមទាំងនោះ ដែលធ្វើឱ្យក្រុមហ៊ុនទាំងនោះ កាត់បន្ថយការប្រកួតប្រជែងរវាងគ្នានិងគ្នា (តួយ៉ាងដូចជា ដំឡើងថ្លៃ ឬកែប្រែធាតុផ្សំផ្សេងទៀតពាក់ព័ន្ធនឹងការប្រកួតប្រជែងរួមមាន គុណភាព និងនវានុវត្តន៍ជាដើម) ដែលករណីនេះ មិនអាចកើតឡើងចំពោះក្រុមហ៊ុនមានកម្មសិទ្ធិករតែមួយឡើយ។ បន្ថែមលើសនេះ អ្នកគ្រប់គ្រងក្រុមហ៊ុនដែលមានកម្មសិទ្ធិរួម នឹងស្ថិតនៅក្រោម ឥទ្ធិពលរបស់ម្ចាស់ភាគហ៊ុនរួមទាំងនោះ។ ឥទ្ធិពលនេះក៏អាចកើតឡើងនៅក្នុងយន្តការអភិបាលកិច្ចសាជីវកម្មជាច្រើនទៀតរបស់ក្រុមហ៊ុននោះ ក្នុងរូបភាពស្រដៀងគ្នា។

លើសពីនេះទៀត ក្នុងទ្រឹស្តីផលប៉ះពាល់កម្មសិទ្ធិរួម អាចបង្កើនសក្តានុពលនៃការឃុបឃិតគ្នា រវាងកម្មសិទ្ធិកររួម ថ្នាក់ដឹកនាំនៃក្រុមហ៊ុនដែលមានកម្មសិទ្ធិរួម ឬក៏ទាំងពីរ។ ក្នុងទ្រឹស្តីនេះ លទ្ធភាពនៃការកើតឡើងនៃការឃុបឃិតគ្នាជាចំហ អាចមានច្រើន ដោយសារតែកម្មសិទ្ធិកររួមទាំងនោះ ទទួលបានការលើកទឹកចិត្ត ក្នុងការដើរតួជាអ្នកដឹកនាំក្រុមហ៊ុនដែលមានកម្មសិទ្ធិរួម ក្នុងការបង្កើតឥទ្ធិពលលើអ្នកគ្រប់គ្រងក្រុមហ៊ុន ដែលពួកគេបានដំឡើងថ្លៃផលិតផល និងសេវាកម្មនោះ (កម្មសិទ្ធិកររួម ដើរតួជាមេក្លោង)។ បន្ថែមលើសនេះ កម្មសិទ្ធិរួម ក៏នឹងជំរុញការឃុបឃិតគ្នាជាសម្ងាត់ រវាងកម្មសិទ្ធិកររួមទាំងនោះ ដោយហេតុថាកម្មសិទ្ធិរួមនេះ អាចបន្ស៊ីការលើកទឹកចិត្តដល់គូប្រជែងក្នុងការអនុវត្តកាតែល (Cartel)។ សេណារីយ៉ូនេះ ជាលទ្ធផលនឹងបង្កឱ្យមានការឃុបឃិតគ្នាជាចំហនៅថ្ងៃណាមួយ។

ដូចគ្នានេះដែរ ទ្រឹស្តីមីក្រូសេដ្ឋកិច្ចបានលើកឡើងថា ក្រុមហ៊ុននៅក្នុងវិស័យកាន់កាប់ដោយវិនិយោគិនដែលមានភាគហ៊ុនជាន់គ្នា នឹងកាត់បន្ថយការប្រកួតប្រជែងគ្នា។ នៅពេលវិនិយោគិនមានភាគហ៊ុនសាជីវកម្មលើសពីមួយ នៅក្នុងវិស័យតែមួយ ពួកគេតែងរំពឹងពីភាពជោគជ័យនៃសាជីវកម្មទាំងអស់នោះ ជាជាងជោគជ័យនៃសាជីវកម្មតែមួយ (ទោះបីជាសាជីវកម្មខ្លះ មានប្រតិបត្តិការល្អប្រសើរឆ្ងាយជាងសាជីវកម្មខ្លះទៀតក៏ដោយ)។ ទ្រឹស្តីមីក្រូសេដ្ឋកិច្ចនេះលើកឡើងថា វិនិយោគិននឹងលើកទឹកចិត្ត ទាំងជាចំហ និងមិនចំហ ឱ្យមានសកម្មភាពប្រតិបត្តិការអាជីវកម្ម ដែលមិនមានការប្រកួតប្រជែងគ្នា ដែលនឹងផ្តល់អត្ថប្រយោជន៍ដល់ក្រុមហ៊ុនដែលពាក់ព័ន្ធ និងវិនិយោគិននៃក្រុមហ៊ុនទាំងនោះ ខណៈសាធារណជន និងអ្នកប្រើប្រាស់

ទូទៅគឺជាអ្នកខាតបង់ចេញពីប្រតិបត្តិការដែលមិនមានការប្រកួតប្រជែងនេះ។ ឧទាហរណ៍ ការស្រាវជ្រាវជាក់ស្តែងលើវិស័យអាកាសចរណ៍ បានបង្ហាញថា ផលប៉ះពាល់នៃកម្មសិទ្ធិរួម គឺការធ្វើឱ្យថ្លៃសំបុត្រយន្តហោះសម្រាប់អ្នកប្រើប្រាស់ កើនឡើងពី ៣% ទៅ ៧% ធៀបនឹងតម្លៃប្រកួតប្រជែងធម្មតា។ បន្ថែមលើលទ្ធផលស្រាវជ្រាវនេះ ការសិក្សាជាក់ស្តែងថ្មីៗ (ក្រុមហ៊ុនអាកាសចរណ៍ Azar / Schmalz / Tecu ជាដើម) ក៏បានបង្ហាញថា បញ្ហាកម្មសិទ្ធិរួមនេះ អាចជះឥទ្ធិពលអាក្រក់ដល់ការប្រកួតប្រជែងទីផ្សារ ក្នុងវិស័យប្រមូលផ្តុំមួយចំនួន ជាពិសេសនៅក្នុងវិស័យអាកាសចរណ៍ ធនាគារផ្តល់កម្ចីទូទៅ និងឱសថស្ថាន ជាដើម។ ច្បាស់ជាងនេះទៅទៀត ឯកសាររបស់ Elhauge និង Azar et al. បានផ្តល់ភស្តុតាងជាក់ស្តែងបន្ថែមលើវិស័យអាកាសចរណ៍ ដែលបង្ហាញថា កម្មសិទ្ធិរួមដែលកាន់កាប់ដោយវិនិយោគិនស្ថាប័នមួយចំនួននឹងធ្វើឱ្យខូចទ្រង់ទ្រាយ នៃកិច្ចការប្រកួតប្រជែងនៅក្នុងរូបភាពជាច្រើន រួមទាំងការឡើងថ្លៃសំបុត្រផងដែរ។ Elhauge ក៏បានចេញផ្សាយឯកសារបន្ថែមស្តីពី ការកាន់កាប់ភាគហ៊ុនខ្សែដេក ក្នុងឆ្នាំ ២០១៨ ដែលបង្ហាញថា ដោយមិនចាំបាច់ឱ្យមានការសម្របសម្រួល ឬការប្រាស្រ័យទាក់ទងគ្នា ការកាន់កាប់ភាគហ៊ុនខ្សែដេក នឹងធ្វើឱ្យអ្នកគ្រប់គ្រងសាជីវកម្មនោះ កាត់បន្ថយកម្រិតប្រកួតប្រជែងដូចនឹងកម្រិតនៃសិទ្ធិបោះឆ្នោត ឬការបោះឆ្នោតឡើងវិញក្នុងក្រុមហ៊ុនរបស់ពួកគេ ដែលធ្វើឱ្យប្រាក់ឈ្នួលរបស់នាយកប្រតិបត្តិ មិនសូវជាអាស្រ័យលើប្រសិទ្ធិភាពនៃការអនុវត្តរបស់ក្រុមហ៊ុនទេ តែផ្តោតជាជាងលើដំណើរការឧស្សាហកម្មរួម។ សរុបមក ការសិក្សាទាំងនេះបានបញ្ជាក់ថា ក្នុងទីផ្សាររួមផ្តាច់មុខ (Oligopolistic Market) ដែលជាកន្លែងដែលដៃគូប្រកួតប្រជែងជាច្រើន មានភាគហ៊ុនរួមគ្នា៖ (១) តម្លៃអាចខ្ពស់ជាងមុន (២) ការឃុបឃិតគ្នាអាចកើតឡើងគ្រប់ពេល និង (៣) ការលើកទឹកចិត្តរបស់អ្នកគ្រប់គ្រងអាស្រ័យ លើការដំណើរការឧស្សាហកម្មរួម ជាជាងប្រសិទ្ធភាពនៃប្រតិបត្តិការរបស់ក្រុមហ៊ុន។

នៅសហរដ្ឋអាម៉េរិក ការសិក្សាសេដ្ឋកិច្ចជាក់ស្តែងចំនួនពីរ បានធ្វើឱ្យមានការជជែកវែកញែកគ្នាច្រើន អំពីឥទ្ធិពលប្រឆាំងការប្រកួតប្រជែង កើតចេញពីបញ្ហាកម្មសិទ្ធិរួម។ ឯកសារស្រាវជ្រាវអំពីទីផ្សារក្រុមហ៊ុនអាកាសចរណ៍អាម៉េរិក បានបង្ហាញថា នៅពេលកម្រិតនៃភាពជាកម្មសិទ្ធិរួមមានការកើនឡើង កម្រិតតម្លៃលក់រាយនៃសំបុត្រយន្តហោះក៏មានការកើនឡើងគួរឱ្យកត់សម្គាល់។ ឯកសារមួយទៀត ដែលសិក្សាពីវិស័យធនាគាររបស់សហរដ្ឋអាម៉េរិក ក៏បានសន្និដ្ឋានស្រដៀងគ្នាថា អត្រាការប្រាក់ និងថ្លៃសេវាសម្រាប់ការដាក់ប្រាក់បញ្ញើធនាគារ មានកម្រិតខ្ពស់ នៅពេលកម្មសិទ្ធិរួម ត្រូវបានគេរកឃើញនៅក្នុងក្រុមហ៊ុនទាំងនេះ។

សរុបសេចក្តីមក ទាំងទ្រឹស្តី និងការសិក្សាស្រាវជ្រាវនានា បានបញ្ជាក់ថា កម្មសិទ្ធិរួមអាចបង្កការរាំងស្ទះដល់កិច្ចការប្រកួតប្រជែង ក្នុងទីផ្សារពោលគឺទ្រឹស្តីនៃឥទ្ធិពលសម្របសម្រួល ទ្រឹស្តីនៃឥទ្ធិពលឯកតោភាគី ក៏ដូចជាទ្រឹស្តីនៃផលប៉ះពាល់។ ដើម្បីធ្វើការវិនិច្ឆ័យ ឱ្យកាន់តែប្រសើរលើឥទ្ធិពលប្រឆាំងនឹងការប្រកួតប្រជែងនៃកម្មសិទ្ធិរួម យើងត្រូវគិតគូរពីកត្តាមួយចំនួនដូចជា ផលប៉ះពាល់សេដ្ឋកិច្ច រចនាសម្ព័ន្ធទីផ្សារដែលពាក់ព័ន្ធ ឥទ្ធិពលលើការសម្រេចចិត្តរបស់អ្នកគ្រប់គ្រង លើការលើកទឹកចិត្ត និងតម្លៃ និងទិដ្ឋភាពពាក់ព័ន្ធផ្សេងទៀត ដែលទាមទារឱ្យមានការសិក្សាស្រាវជ្រាវជាក់ស្តែងបន្ថែមទៀត។

## COMMON OWNERSHIP AND COMPETITION LAW'S INFRINGEMENTS

By Mr. Keo Buntheng
Chief of Commercial Law Bureau
Department of Legal Affairs

Common ownership occurs where a common set of large, diversified financial investors simultaneously hold non-controlling minority equity shares or ownership interests in several competing firms (India Business Law Journal, 2020). The common ownership, sometimes referred to as horizontal shareholding, is a term that reflects the investment practice of many institutional investors to hold investment positions in more than one company competing in the same sector (Dallas., G, 2018).

Due to its complicated nature, there are various debates among competition authorities globally; for instance, the European Commission has taken common ownership into account in two recent high-profile merger cases, namely Dow / DuPont (2017) and Bayer / Monsanto (2018); the US Federal Trade Commission held a hearing on common ownership which led to strong reactions from investors and index providers; and the common ownership and its impact on competition was also a topic at the OECD roundtable discussion at the end of 2017. Currently, common ownership is one of the focus issues in countries where competition law exists as academicians and practitioners are increasingly concerned by the effect of common ownership on competition. With regards to its impact, it is believed that the common ownership always amounts to the infringements of the competition law based on some evidences and reasons below.

According to the theory of coordinated effects, common ownership could increase the potential for collusion among common owners or the managements of commonly owned firms, or both. It suggests that common ownership could encourage the common owner to facilitate coordination by its portfolio of companies. In principle, the coordinated effects occur when, in the presence of given market conditions (e.g. market transparency, product homogeneity, etc.), the merger or acquisition increases the probability that, post-transaction, merging parties and their competitors, or the acquirer and its competitors may successfully be able to coordinate their behavior in an anticompetitive way, for example, by raising prices (FRAZZANI, S. et al, 2020).

Similarly, the theory of unilateral effects suggests that the common shareholding may lead to short-term price increases and a decline in quality, variety or innovation, due to fewer incentives to compete. In this regard, potential anticompetitive effects can present themselves in the form of unilateral effects (i.e. arise from the individual conduct of the commonly owned firms). Under such theory, by virtue of their simultaneous holdings in competitors' shares, common shareholders, unlike a single owner, have an interest in the profits of competitor firms whose shares they own. This may, from a portfolio standpoint, give them an incentive to prompt the management of these rival firms to engage in less vigorous competition in the relevant market. The proponents of the unilateral effects' theory argue that, by the very structure of the common shareholdings, common owners would also have the ability to influence the management of commonly owned firms to compete less with one another (e.g. by raising prices or negatively impacting other parameters of competition, such as quality or innovation) than would be the case under a single firm owner scenario. In addition, commonly owned firms' management would be receptive to such common shareholders' influence. Various corporate governance mechanisms could be the channels through which such influence is exercised (FRAZZANI, S. et al, 2020).

Furthermore, under the theory of harm, it is provided that common ownership increases the potential for collusion among common owners, managements of commonly owned firms, or both. Under this theory of harm, explicit collusion would become more likely, since common owners would have incentives to act as a conduit for commonly owned firms to influence managers of firms they own to raise prices ("common owners as a ringleader" theory of harm). In addition, common ownership can foster tacit collusion among common owners because it can align the incentives of competitors to run a stable cartel. This, in turn, can make explicit collusion more successful.

In the same regard, the microeconomic argument suggests that firms in a sector owned by overlapping sets of investors have reduced incentives to compete. When investors have more than one corporate holding within the same sector, it stands to reason that they hope all of these corporates are successful, not just one (even though some will inevitably perform better than others). This microeconomic theory suggests that investors, will encourage, explicitly or implicitly, anti-competitive practices that benefit the companies involved—and their investors—at the expense of consumers and the public good more generally. For instance, the empirical research on airline sector has suggested that the impact of common ownership was to inflate the cost airline tickets for consumers by 3-7% relative to normal competitive pricing. Echoing this finding, some recent empirical studies (the Azar / Schmalz / Tecu Airlines, etc) have concluded that common ownership may have a detrimental effect on market competition in certain concentrated sectors, particularly in airlines, retail banking and pharma. To be precise, the papers of Elhauge and Azar et al., produced empirical evidence focusing on the airline sector suggesting that common ownership by institutional investors results in distorted competition along several factors, including ticket prices. Elhauge also issued a further paper on horizontal shareholding in 2018, defending his arguments from his critics, and presenting "economic proofs" which shows that "without any need for coordination or communication, horizontal shareholding will cause corporate managers to lessen competition to the extent they care about their vote share or re-election odds and will cause executive compensation to be based less on firm performance and more on industry performance." In brief, these studies find that in oligopolistic markets where competitors have shareholders in common (1) prices may be higher, (2) collusion may be more likely and (3) management incentives may be oriented towards industry performance and not firm performance.

In the US, two empirical economic studies sparked a debate on the potential anticompetitive effects of common ownership. In a paper focused on evidence from the US airline market, scholars showed that there was a statistically significant increase in the retail price level when the levels of common ownership increase (Azar et al, 2018). In another paper, focused on the US banking sector, scholars concluded that interest rates and fees for banking deposit services were higher when the pattern of common ownership was present (Azar, Raina et al, 2016).

In conclusion, there are various theories and literatures proving that the common ownership can cause potential harm to the competition in the market, namely the theory of coordinated effects, the theory of unilateral effects, as well as the theory of harm. To make better judgement on anti-competitive effects of the common ownership, we need to take into consideration some factors such as the economic impacts, relevant market structure, the influence on management's decisions on incentives and prices, and other related aspects which require more empirical researches.

# ផលប៉ះពាល់ជាសក្តានុពលរបស់កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ ( អាសិប ) និងបរិវត្តកម្មរចនាសម្ព័ន្ធមកលើកម្ពុជា

សនជ្រៃ មុហ្កាន ថាងកាវ៉ាលូ
ហ៊ីង វុត្ថា
ខូវ អៀហៃ
ខុង ប៊ុនរ័ត្ន
ទិត សីច័ន្ទលី

## សេចក្តីសង្ខេប

ការសិក្សាស្រាវជ្រាវនេះធ្វើការវិភាគផលបច្ច័យរបស់អាសិប លើសេដ្ឋកិច្ចប្រទេសកម្ពុជាពាក់ព័ន្ធនឹងពាណិជ្ជកម្ម កំណើនទិន្នផល និងការងារ។ ការស្រាវជ្រាវនេះត្រូវបានវិភាគបែបបរិមាណ ( structural gravity model estimations and simulation ) និងបែបគុណភាព–ការវាយតម្លៃគោលនយោបាយពាណិជ្ជកម្មពាក់ព័ន្ធការនាំចេញ ទិន្នផល និងការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចនៅក្នុងខ្សែច្រវាក់តម្លៃសកល និងតំបន់។ លទ្ធផលបានបង្ហាញពី ឥទ្ធិពលវិជ្ជមានរបស់អាសិបមកលើសេដ្ឋកិច្ចកម្ពុជា។ កម្ពុជានឹងទទួលផលវិជ្ជមានច្រើន ទៅលើសេដ្ឋកិច្ចក្នុងស្រុក ជាមួយនឹងការកែទម្រង់ស៊ីជម្រៅ លើកិច្ចសម្រួលពាណិជ្ជកម្ម និងការវិនិយោគ និងការកែទម្រង់ក្នុងស្រុក។ លទ្ធផលក៏បានបង្ហាញពីសារសំខាន់នៃអាសិប លើជំងឺរាតត្បាតកូវីដ១៩ ការស្តារឡើងវិញក្រោយជំងឺរាតត្បាតនេះ និងការផ្លាស់ប្តូររចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជា។

ការសិក្សាស្រាវជ្រាវនេះក៏បានផ្តល់នូវអនុសាសន៍សំខាន់ៗជាគោលនយោបាយផងដែរ ដើម្បីបង្កើនអត្ថប្រយោជន៍ជាអតិបរមានៃអាសិប សម្រាប់កំណើនប្រកបដោយចីរភាព និងបរិយាប័ន្ននៅក្នុងប្រទេសកម្ពុជា៖

- ( i ) តម្រូវការក្នុងការបង្កើនភាពប្រកួតប្រជែង និងការផ្សារភ្ជាប់តំបន់សេដ្ឋកិច្ចពិសេសទៅនឹងសកម្មភាពខ្សែច្រវាក់តម្លៃសកល ដើម្បីទាក់ទាញសកម្មភាពក្រុមហ៊ុនពហុជាតិនៅក្នុងឧស្សាហកម្មទាំងនេះ។
- ( ii ) តម្រូវការក្នុងការកែលម្អ និងបង្កើនការផ្សារភ្ជាប់ទំនាក់ទំនងខ្សែច្រវាក់តម្លៃសកល ដូចជាការតភ្ជាប់សេវាឡូហ្ស៊ីស្ទិក ហេដ្ឋារចនាសម្ព័ន្ធ និងការបង្កើនការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុកក្នុងសកម្មភាពខ្សែច្រវាក់តម្លៃសកល ក្នុងតំបន់ ដោយសារការភ្ជាប់សេវាឡូហ្ស៊ីស្ទិកមានសារសំខាន់សម្រាប់ចលនាទំនិញកម្រិតមធ្យមក្នុងសកម្មភាពតម្លៃបន្ថែមខ្ពស់។

(iii) សារសំខាន់នៃការអភិវឌ្ឍជំនាញបច្ចេកទេស នឹងជំនាញវិជ្ជាជីវៈដែលបំពេញបន្ថែម និងបង្កើនការទទួលយកបច្ចេកវិទ្យាថ្មី នៅក្នុងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ - ដើម្បីផ្តល់ធនធានមនុស្សរឹងមាំ និងកម្លាំងពលកម្មពាក់កណ្តាលជំនាញ និងជំនាញ ដែលជំរុញសកម្មភាពតម្លៃបន្ថែមខ្ពស់ ដែលមានសារសំខាន់សម្រាប់ប្រទេសកម្ពុជាក្នុងដំណាក់កាលនៃការអភិវឌ្ឍនេះ។

(iv) តម្រូវការក្នុងការធ្វើឱ្យស្របទៅនិងសេវាកម្មឧស្សាហកម្មក្នុងស្រុក ដែលគាំទ្រសកម្មភាពផលិតកម្មជាមួយសកម្មភាពខ្សែច្រវាក់តម្លៃសកលនៃការតភ្ជាប់ចិន ជប៉ុន កូរ៉េ (CJK) ដោយសារតែវិស័យឡូហ្ស៊ីស្ទិក និងសកម្មភាពដឹកជញ្ជូនត្រូវបានគេរំពឹងថានឹងកើនឡើងជាមួយនឹងសកម្មភាពខ្សែច្រវាក់តម្លៃសកលដែលជំរុញដោយការតភ្ជាប់ CJK ។ និង

(v) តម្រូវការដើម្បីធ្វើការកែទម្រង់ពាណិជ្ជកម្មប្រពៃណីលើសេវាកម្មដូចជា ទេសចរណ៍ ឡូហ្ស៊ីស្ទិក អាកាសចរណ៍ ហិរញ្ញវត្ថុ និងទេសចរណ៍វេជ្ជសាស្ត្រ ដោយសារពាណិជ្ជកម្មសេវាកម្មពឹងផ្អែកខ្លាំងលើការចល័តរបស់មនុស្ស (ម៉ូឌទី៤) ដើម្បីរក្សាការប្រកួតប្រជែងនៅក្នុងតំបន់ និង ការផ្លាស់ប្តូរទៅជា គន្លងប្រក្រតីភាពថ្មី នៅក្នុងយុគសម័យក្រោយជំងឺរាតត្បាតនឹងកាត់បន្ថយសកម្មភាពក្នុងពាណិជ្ជកម្មសេវាកម្មប្រពៃណី។

សូមស្កេនទីនេះដើម្បីទាញយកអត្ថបទស្រាវជ្រាវនេះ។

# POTENTIAL IMPACT OF RCEP AND STRUCTURAL TRANSFORMATION ON CAMBODIA

Shandre Mugan Thangavelu

Vutha Hing

Ea Hai Khov

Bunroth Khong

Seychanly Tith

**Summary**

This paper analyses the impact ofthe RCEP on the Cambodian economy in terms of trade, output growth, and employment. This is done through quantitative (structural gravity model estimations and simulation) and qualitative analysis –a trade policy evaluation in terms of exports, output, and structural transformation of the economy inthe global and regional value chain. The results indicate a positive impact of the RCEP on the Cambodian economy. The Cambodian economy will experience larger positive impact on the domestic economy with deeper trade and investment facilitation and domestic reforms. The results highlightthe importance of the RCEP for the pandemic and post-pandemic recovery and structural transformation of the Cambodian economy.

The paper also provides key policy recommendations to maximise the benefits of the RCEP for inclusive and sustainable growth in Cambodia:

(i) the need to increase the competitiveness and linkages of Special Economic Zones to GVC activities to attract multinational activities in these industries;
(ii) the need to improve and increase GVC linkages such as logistics service linkages, infrastructure, and increased domestic SME participation in regional GVC activities, as logistics servicelinkages are critical for the movement of intermediate goods in higher value-added activities;
(iii) theimportance of technical and vocational skills development that complements and increases the adoption of new technologies in higher value-added industries – to provide strong human capital and semi-skilled and skilled labour force that drives higher value-added activities, which is critical forCambodia at this stage of development;
(iv) the need to align domestic service industries supporting manufacturing activities with CJK GVC activities, as logistics and transportation activities are expected to increase with the GVC activities driven by CJK; and
(v) the need to reform traditional trade in services such as tourism, logistics, aviation, financial, and medical tourism, as trade in services relies heavily on the movement of people (mode 4) to remain competitive in the region, and the transformation to a 'new' normal in the post-pandemic era will reduce activities in traditional servicestrade.

Scan here to
download full article.

# About the iTrade Bulletin

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world. This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


**Honorable President**
H.E. Mr. PAN Sorasak

**Editorial Board**
- H.E. Mrs. CHAM Nimul (Chairwoman)
- H.E. Ms. SEREI Borapich
- Mr. HOR Iengchhay
- Mr. SOK Bunthorn

**Advisors**
- H.E. Mr. SIM Sokheng
- H.E. Mr. PENN Sovicheat
- H.E. Dr. TAT Puthsodary
- H.E. Prof. Shandre Mugan THANGAVELU

**People behind iTrade Bulletin**
- Mr. PAO Phireak
- Mr. CHINKET Tola
- Ms. YANGNY Chakriya
- Ms. CHEA Kunlak
- Ms. PHAL Yita
- Mr. LY Rithy
- Mr. SE Sokunvathna
- Mr. NY Atykunn


# Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

## Topics Covered:

- Domestic and International Trade
- Domestic and International Economics
- 4th Industrial Revolution (4IR) and Technology
- Social Issue
- Gender Equality
- Other relevant topics.

## Categories:

- Research articles
- Case reports
- Policy Briefs
- Commentaries or editorial

For more information, please scan


វិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ - TTRI

https://ttri.info/

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA